01218332

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 03 / 2016
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E305/10/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្ដីសម្រេចទៅលើការជំទាស់របស់សហព្រះរាជអាជ្ញាជាតិទៅនឹងសាក្សី និង អ្នកជំនាញដែលបានស្នើសុំដោយភាគីដទៃ

១. អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យលើការជំទាស់របស់សហព្រះរាជអាជ្ញាជាតិទៅនឹងសាក្សី និង អ្នកជំនាញដែលត្រូវបានស្នើសុំដោយភាគីដទៃ (ឯកសារ E305/10)។ សហព្រះរាជអាជ្ញាជាតិបានជំទាស់ទៅនឹងសាក្សី 2-TCW-831, 2-TCW-951 និង ជា ស៊ឹម (2-TCW-878) ដែលត្រូវបានស្នើសុំដោយក្រុមមេធាវីការពារក្ដី នួន ជា ដោយផ្អែកលើមូលដ្ឋានថា មេធាវីការពារក្ដី នួន ជា ខកខានមិនបានផ្ដល់យុត្តិកម្មអំពីភាពចាំបាច់ក្នុងការកោះហៅសាក្សីដែលបានស្នើឡើងទាំងនេះ ហើយថាសក្ខីកម្មរបស់សាក្សីអាចនឹងមានភាពច្រំដែល និង អូសបន្លាយកិច្ចដំណើរការនីតិវិធីដោយមិនចាំបាច់។ សហព្រះរាជអាជ្ញាជាតិបានលើកឡើងបន្ថែមទៀតថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងពិចារណាទៅឃើញថាភ័ស្តុតាងដែលទទួលបានពីពួកគាត់ទាំងបីរូប មានភាពចាំបាច់ខ្លាំង អង្គជំនុំជម្រះអាចស្នើឲ្យមានចម្លើយជាលាយលក្ខណ៍អក្សរ

ជំនួសឱ្យការចូលខ្លួនដោយផ្ទាល់របស់ពួកគាត់នៅចំពោះមុខតុលាការ (ឯកសារ E305/10 កថាខណ្ឌ ៣)។

២. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា អង្គជំនុំជម្រះបានពន្យារការសម្រេចទៅលើសំណើសុំស្តាប់សក្ខីកម្មសាក្សី 2-TWC-831 និង 2-TCW-951 ទៅពេលសមស្របណាមួយក្នុងអំឡុងកិច្ចដំណើរការនីតិវិធីខាងមុខ (សូមមើល ឯកសា E370/3)។

៣. ចំពោះសាក្សី ជា ស៊ីម (2-TCW-878) អង្គជំនុំជម្រះកត់សម្គាល់ថា គាត់បានទទួលមរណភាពកាលពីថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ ហើយ (Saing Soenthrith "លោក ជា ស៊ីម ប្រធានគណបក្សប្រជាជនកម្ពុជាទទួលមរណភាព" កាសែត Cambodia Daily ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១៥ គេហទំព័រ https://www.cambodiadaily.com/archives/cpp-president-chea-sim-dead-85182/)។ អាស្រ័យហេតុនេះ ការជំទាស់ និង សំណើផ្សេងៗរបស់សហព្រះរាជអាជ្ញាជាតិ ពាក់ព័ន្ធនឹងសាក្សីរូបនេះ គឺត្រូវចាត់ទុកជាអសារបង់។

៤. ឯកសារនេះគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E305/10។